# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៤១៥
ចុះថ្ងៃទី ១៤-៦-២០១០
សាលដីកា
លេខ: ៨៣ - ក្រV ប ស-
ចុះថ្ងៃទី ១៧-៧-២០១២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បង្កើតឡើង តាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ២០-៦-២០១២ ដែលមានសមាសភាពដូចខាងក្រោម ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខៈ ៤១៥ ចុះថ្ងៃទី ១៤-៦-២០១០ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ[redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីលក់ដូរ កើតនៅភូមិចុងខ្លុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ មានទីលំនៅបច្ចុប្បន្នភូមិចុងខ្លុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ឪពុកឈ្មោ[redacted]ស) ម្តាយឈ្មោះ[redacted]) ប្រពន្ធឈ្មោះ[redacted]មានកូន ០១នាក់ ទោសពីមុនគ្មាន ។

២-ជនជាប់ចោទឈ្មោះ[redacted] ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរឥស្លាម កើតនៅភូមិត្រពាំងខ្លុង ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ចាម មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្ននៅភូមិចុងខ្លុយ ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ឪពុកព[redacted] ម្តាយឈ្មោះ[redacted](រ) ប្រពន្ធឈ្មោះ[redacted]កូន ៧នាក់ ទោសពីមុនគ្មាន ។

-ជនជាប់ចោទទាំងពីរមានលោ[redacted]មធាវីការសិទ្ធិជនជាប់ចោទ ។





Scanned by CamScanner

ជាប់ចោទពីបទៈ មនុស្សឃាដគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិសាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទ ឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ទស្រី អាយុ ៥០ឆ្នាំ ជាតិខ្មែរ នៅភូមិ ក្រាំងតាសែន សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។

-ដោយមានលោក[redacted]និងលោក[redacted]ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

## ឯរឿងហេតុមានដូចតទៅ

**សកម្មភាព** ប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅៈ

កាលពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ ជនរងគ្រោះឈ្មោ[redacted]នធ្វើដំណើរមកពីលេងផ្ទះកូននៅភូមិចុងខ្លង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ដោយជិះម៉ូតូលើកំណាត់ផ្លូវជាតិលេខ ៥ ឆ្ពោះមកទីរួមខេត្តពោធិសាត់។ លុះមកដល់ភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិ៍សាត់ នៅវេលាម៉ោង១១ និង៣០នាទី មានជនល្មើសចំនួន ០២នាក់ ជិះម៉ូតូឌុបគ្នាមកតាមក្រោយដល់កៀកបានបាញ់ជនរង-គ្រោះ នឹងកាំភ្លើងខ្លី ១គ្រាប់ ត្រូវក្រោមឆ្អឹងជំនីខាងឆ្វេងបណ្តាលឲ្យរបួសធ្ងន់ និងបណ្តាល ឲ្យស្លាប់ក្រោយពីបានសង្គ្រោះនៅមន្ទីរពេទ្យ ។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខៈ ០៤ "ជ" ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ឲ្យឈ្មោះ [redacted]ខ្លួនពីបទចោទ ពីបទ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាល ពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាម មាត្រា ៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

២-លើកចោលការប្តឹងទាមទារជម្ងឺចិត្ត របស់អ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ចំនួន ១០.០០០ (ដប់ពាន់) ដុល្លាអាមេរិក ពីជនជាប់ចោទឈ្មោ[redacted]យខុសទៅនិងតតិច្បាប់ ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ និងអ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១០ កំបាំងមុខជនជាប់ចោទ និងអ្នកតំណាងដោយអាណត្តិ ដើមបណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ របស់លេ[redacted]តំណាងអយ្យការ សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខៈ ០៤ "ជ" ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ គ្រង់ចំណុចទាំងមូល នៃសាលក្រម ។

**បានឃើញ** របាយការណ៍សំណុំរឿងព្រហ្មទណ្ឌលេខៈ ៨១៥ ចុះថ្ងៃទី ១៤-៦-២០១០ របស់ចៅក្រមរបាយការណ៍ នៃសាលាឧទ្ធរណ៍ ។



Scanned by CamScanner

**បានឃើញ** សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ២២.១២.២០១០ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**បានឃើញ** សាលដីការបៀបលេខ ០៣ ក្រ V បស ចុះថ្ងៃទី ២៧.៧.២០១១

## **នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាអានសាលដីការបៀបលេខ ០៣ ក្រvបស ចុះថ្ងៃទី ២៧.៧.២០១១

-ជនជាប់ចោទឈ្មោះ [redacted] (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] (អវត្តមាន)

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលោក [redacted] (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

-មេធាវីការពារឈ្មោះ [redacted] (វត្តមាន)

-មេធាវីការពារឈ្មោះ [redacted] (វត្តមាន)

-កូនរបស់ជនរងគ្រោះឈ្មោះ [redacted] (វត្តមាន)

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted]

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted]

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted]

-ឈ្មោះ [redacted] ជាកូនរបស់ជនរងគ្រោះបានឆ្លើយថា មុននឹងឪពុកខ្ញុំស្លាប់ទៅគាត់ប្រាប់ថា ឈ្មោះ [redacted] ជាអ្នកដេញបាញ់គាត់។ ជនជាតិចាមគឺគេប្រើឈ្មោះប្រពន្ធជាគោល ព្រោះប្តីមានត្រកូលដូចៗគ្នា ទើបគេប្រើឈ្មោះប្រពន្ធមុនប្តីដាក់ឈ្មោះហៅក្រោយ នេះជាទម្លាប់របស់ជនជាតិ។ រូបភាពនិងស៊ីឌីថតសម្លេងបានបញ្ចូលជាភស្តុតាងរួចហើយ ។

## **សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនរងគ្រោះ**

-មេធាវីលោក [redacted] បានធ្វើសេចក្តីសន្និដ្ឋាន ពេលវេលាដែលបានបញ្ជាក់ទាំងសាក្សីនិងពេលវេលាដែលជនរងគ្រោះបញ្ជាក់ គឺពេលវេលាត្រូវគ្នាជាក់លាក់ស៊ីសង្វាក់គ្នាដែលជនរងគ្រោះលើកឡើងមុនស្លាប់ ព្រោះកើតហេតុនៅចន្លោះម៉ោង ១០ ថ្ងៃ ទៅម៉ោង ១១ និង៤៥នាទី សូមក្រុមប្រឹក្សាពិចារណា។

-មេធាវីលោក [redacted] បានធ្វើសេចក្តីសន្និដ្ឋាន រឿងក្តីនេះកើតឡើងដោយមានគំនុំលើកូនក្តីខ្ញុំ សម្តីចុងក្រោយរបស់ជនរងគ្រោះបានឆ្លើយរួចហើយមុននឹងស្លាប់គាត់ឆ្លើយថាឈ្មោះ [redacted] សម្លាប់គាត់។ សូមផ្តល់យុត្តិធម៌ដល់កូនក្តីខ្ញុំ។

## **សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ**

អង្គហេតុជនរងគ្រោះបានឆ្លើយបញ្ជាក់ថាឈ្មោះ [redacted] ងឈ្មោះ [redacted] ដោយបញ្ជាក់ទាំងឈ្មោះប្រពន្ធជនជាប់ចោទទៀតផង ពេលវេលាកាលទេសៈ ប្រព្រឹត្តម៉ោង១១ថ្ងៃ ជនរងគ្រោះស្លាប់ភ្លាមៗ ហេតុនេះគួបដិសេធសាលក្រមសាលាដំបូងសុំទោសប្រកាន់ដូចដែលអយ្យការសាលាដំបូងបានចោទ ប្រកាន់។



Scanned by CamScanner

76/1

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-មេធាវីការពារលោក [redacted] ឆ្លើយការពារថា: ថ្ងៃកើតហេតុនៅចន្លោះម៉ោង ១១ ស៊ីសង្វាក់ជាមួយសាក្សី ប៉ុន្តែពេលវេលារបស់ជនជាប់ចោទវាខុសគ្នាទៅនិងពេលវេលារបស់ជនរងគ្រោះដែលបានឆ្លើយ ភស្តុតាងជាគ្រាប់កាំភ្លើង សំបកគ្រាប់ ស្នាមរបួសដែលបាញ់ត្រូវ ក៏ពុំឆ្លើយជាក់លាក់នោះទេ សូមតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងខេត្តពោធិ៍សាត់។

-ក្រោយពីបានស្ដាប់អំណានរបាយការណ៍រឿង
-ក្រោយពីបានស្ដាប់អំណានសាលដីការបៀប
-ក្រោយពីបានស្ដាប់អំណានចម្លើយសាក្សី
-ក្រោយពីបានស្ដាប់ចម្លើយរបស់កូនជនរងគ្រោះ
-ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់មេធាវីការពារឲ្យដើមបណ្ដឹង
-ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្ដី
-ក្រោយពីបានពិភាក្សាពិចារណាត្រឹមត្រូវតាមច្បាប់ ។

## សាលាឧទ្ធរណ៍យល់ឃើញថា

១-បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ជាតំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះ ។

២-កាលពីថ្ងៃទី ១១-៦-២០០៩ ឈ្មោះ [redacted] ជនរងគ្រោះបានធ្វើដំណើរមកពីលេងផ្ទះកូននៅភូមិចុងខ្លង ឃុំអូរសណ្ដាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដោយជិះម៉ូតូតាមផ្លូវជាតិលេខ ៥ មកទីរួមខេត្តពោធិ៍សាត់។ ពេលជិះមកដល់ភូមិសាលាត់រួមានជនល្មើស ២នាក់ ជិះម៉ូតូឌុបគ្នា តាមពីក្រោយជនរងគ្រោះមកអែបជនរងគ្រោះ ហើយបានបាញ់ជនរងគ្រោះ ១គ្រាប់ ត្រូវក្រោមឆ្អឹងជំនីខាងឆ្វេងបណ្ដាលឱ្យរបួសធ្ងន់ ហើយបញ្ជូនទៅព្យាបាលនៅពេទ្យ។ រយៈពេលសំរាកព្យាបាលនៅមន្ទីរពេទ្យជនរងគ្រោះបាននិយាយប្រាប់ថាអ្នកបាញ់ខ្លួនគឺគាត់ស្គាល់មាន [redacted] ប្រពន្ធឈ្មោះ [redacted] និងម្នាក់ទៀតឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] នៅថ្ងៃទី ១៣-៦-២០០៩ ជនរងគ្រោះបានស្លាប់នៅមន្ទីរពេទ្យខេត្តបាត់ដំបង។

៣-តាមការស៊ើបអង្កេតស្រាវជ្រាវរបស់សមត្ថកិច្ចជនជាប់ចោទមានឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានឈ្មោះ [redacted] ទប្រុស អាយុ ២៦ឆ្នាំ ជនជាតិឥស្លាម និងជនជាប់ចោទឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] គឺមានឈ្មោះ [redacted] ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិឥស្លាម អ្នកទាំងពីររស់នៅភូមិចុងខ្លង ឃុំអូរសណ្ដាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។

៤-តាមការអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] នាពេលសវនាការសាលាដំបូងថា នៅថ្ងៃទី ១៦-៦-២០០៩ ខ្លួនបានបើកឡានជូនប្រពន្ធទៅលក់ចានឆ្នាំង តាំងពីព្រលឹមពេលជូនរួចហើយត្រឡប់មកវិញ។ នៅថ្ងៃនោះចន្លោះម៉ោង ១០ព្រឹក រហូតដល់ម៉ោង ១២ ថ្ងៃត្រង់ ខ្លួនមិនបាន ចេញទៅណា



Scanned by CamScanner

ទេ គឺនៅបោកខោអាវ ងូតទឹក ហូបបាយផ្ទះ បន្ទាប់មកចូលថ្វាយបង្គំព្រះដែលនៅក្បែរផ្ទះ។ នៅម៉ោង ១២ ជាង នគរបាលបានមកហៅទៅសាកសួរនៅប៉ុស្តិ៍នគរបាលអូរសណ្តាន់ ។

៥-តាមការអះអាងរបស់ជនជាប់ចោទឈ្មោះ[redacted]ពេលសវនាការសាលាដំបូងថា នៅថ្ងៃទី ១១-៦-២០០៩ ចន្លោះម៉ោង ១១ ទៅ ១២ ថ្ងៃត្រង់ ខ្លួនផឹកកាហ្វេក្នុងតៀមកាហ្វេក្បែរសាលាឃុំអូរសណ្តាន់ មានសាក្សីច្រើននាក់ដែលផឹកកាហ្វេជាមួយគ្នាពិសេសឈ្មោះ[redacted]ជានាយនគរបាលប៉ុស្តិ៍ក៏ផឹកកាហ្វេទីនោះដែរ ហើយមានចម្ងាយពីទីតាំងកើងហេតុ។

៦-តាមសាលដីកាព្រហ្មទណ្ឌរបៀបលេខៈ ០៣ "ក្រ.បស" ចុះថ្ងៃទី ២៧-៧-២០១១ របស់សាលាឧទ្ធរណ៍ ដែលបានចាត់ឱ្យស៊ើបសួរបន្ថែម នោះតុលាការបានធ្វើការស៊ើបសួរបន្ថែមឃើញថាៈ

ក-តាមចម្លើយរប[redacted]យកផ្នែកពិនិត្យវិភាគនៃអធិការដ្ឋាននគរបាលក្រុងពោធិ៍សាត់ បានបញ្ជាក់ថានៅថ្ងៃទី ១១-៦-២០០៩ ខ្លួនមិនបានមើលម៉ោងទេ ពេលចេញពីអធិការដ្ឋានទៅមើលកន្លែងកើតហេតុតាមបញ្ជារលោកអធិការក្រុងពោធិ៍សាត់ ទៅកន្លែងកើតហេតុប្រហែល ៧ និង ១០នាទី។ ពេលដល់កន្លែងកើតហេតុឃើញមានប្រជាជនអ៊ូរអរ ហើយខ្ញុំដើរពិនិត្យកន្លែងកើតហេតុបន្តិច ទើបចាប់ផ្តើមធ្វើកំណត់ហេតុដោយមើលម៉ោងក្នុងទូរស័ព្ទ ឃើញថាម៉ោង ១១និង១០នាទី។ តាមការបញ្ជាក់របស់ឈ្មោះ[redacted]ថាពេលកើតហេតុប្រព្រឹត្តឡើងនៅមុនម៉ោង ១១ ព្រឹក។

ខ-តាមចម្លើយរបស់ឈ្មោះ[redacted]ាមេប៉ុស្តិ៍នគរបាលរដ្ឋបាលព្រៃឈើថា នៅថ្ងៃទី ១១-៦-២០០៩ ម៉ោង ១១ និង ៣០នាទី ខ្លួនបានទទួលដំណឹងពីមេភូមិសាលាគំរូឈ្មោះ[redacted]តាមរយៈទូរស័ព្ទថាមានឧក្រិដ្ឋបាញ់សម្លាប់លើផ្លូវជាតិលេខ ៥ ។ ពេលវេលាដែលបញ្ជាក់ក្នុងកំណត់ហេតុជាពេលវេលាដែលបានទទួលដំណឹងមិនពិតមែនជាពេលវេលាដែលឃាតករបាញ់លើជនរងគ្រោះទេ។ រយៈពេលធ្វើដំណើរបើកម៉ូតូលឿនពីឃុំព្រៃញី ទៅកន្លែងកើតហេតុប្រហែលរយៈពេល ១៥នាទីទៅ ២០នាទី។

គ តាមចម្លើយរបស់ឈ្មោះ[redacted]បានបញ្ជាក់ថា ខ្លួនមិនចាំថ្ងៃខែឆ្នាំទេ ពេលព្រឹកម៉ោងប្រហែល ១០ និង ៣០នាទី ខ្លួនចេញពីធ្វើការ ហើយទៅផឹកកាហ្វេ នៅភូមិអូរអាចម៌គុក ម៉ោងប្រហែល ១១ និង៣០នាទី ក្រោយមកប្រហែល ៥នាទី ឈ្មោះ[redacted]ជាទំនប់ទី១ មកដល់ផឹកកាហ្វេជា [redacted]មកដល់តំណាលគ្នាដែរ ហើយអង្គុយផឹកកាហ្វេនិយាយគ្នាលេង ដោយឈ្មោះ ត[redacted]សួរឈ្មោះ[redacted]ពីណាឈ្មោះ[redacted]ឆ្លើយថាមករកមើលទិញគោរបស់ឈ្មោះ[redacted] ការផឹកកាហ្វេរយៈពេលប្រហែល ២០នាទី ទើបបែកគ្នា។ ម៉ោងប្រហែល ១២ និង ៣០នាទី បានទទួលបញ្ជាពីអធិការឱ្យរកឈ្មោះ[redacted]ខ្លួនក៏បានទៅជួបឈ្មោះ[redacted] នៅផ្ទះ ហើយទទួលបញ្ជាឱ្យចាប់ឈ្មោះ[redacted]មិនហ៊ានចាប់ព្រោះទៅតែម្នាក់ ឯងហើយប្រាប់ឈ្មោះ[redacted]ក្លីនៅប៉ុស្តិ៍រដ្ឋបាលអូរសណ្តាប់។

៧-តាមការអះអាងរបស់ប្រជាជនដែលបានផ្តិតមេដៃលើលិខិតគាំទ្រ (ឯកសារលេខ ២០/២១) បានបញ្ជាក់ថា នៅថ្ងៃទី ១១-៦ ២០០៩ ម៉ោងប្រហែល ១១ រហូតដល់ម៉ោង ១២ជាង ឈ្មោះ[redacted] នៅផ្ទះពុំបានចេញទៅណាទេ ដែលអះអាងនេះផ្ទុយពីឈ្មោះ[redacted]ដែលអះអាងថា ម៉ោងប្រហែល ១១ និង ៣០នាទី ឈ្មោះ[redacted]នៅផឹកកាហ្វេជាមួយខ្លួន

ហើយឈ្មោះ[redacted]បានបញ្ជាក់ថា ចាប់ពីម៉ោង ១១ព្រឹក រហូតដល់ម៉ោង ១២ថ្ងៃត្រង់ខ្លួន បាន ចេញទៅផឹកកាហ្វេជាមួយឈ្មោះ[redacted]

៨-តាមញ្ញាត្តិគាំទ្ររបស់ប្រជាជន (ឯកសារលេខ ២១) បានបញ្ជាក់ថា ម៉ោង ៩ ព្រឹករហូតដល់ម៉ោង ១២ និង ១៥នាទី ឈ្មោះ[redacted]នៅក្នុងភូមិរហូត ដល់ម៉ោង ១២ និង ១៥នាទី ទើបចុះពីព្រះវិហារ ប៉ុន្តែតាមចម្លើយរបស់ឈ្មោះ[redacted](ឯកសារ ៣៣) បញ្ជាក់ថាមុនពេលខ្លួនផឹកកាហ្វេនៅភូមិអូរអាចមន៍គុក ខ្លួនយកឪសទៅធ្វើនៅភូមិពុទ្រាម ដូច្នេះអាចបញ្ជាក់ឱ្យឃើញថាឈ្មោះ[redacted]មិននៅក្នុងភូមិជាប់រហូតដូចការអះអាងក្នុងញ្ញត្តិគាំទ្រ (ឯកសារ២១) នោះឡើយ។

៩-ផ្អែកតាមចម្លើយសាក្សី ភស្តុតាងនានា ដែលប្រមូលបានព្រមទាំងចម្លើយជនរងគ្រោះមុនពេលស្លាប់ អាចបញ្ជាក់ឱ្យឃើញថាអំពើឃាតកម្មនោះកើតឡើងមុនម៉ោង ១១ ព្រឹក ហើយការអះអាងរបស់ជនជាប់ចោទឈ្មោះ[redacted]នផឹកកាហ្វេជាមួយឈ្មោះ[redacted] ប៊ុនសម្បត្តិ ចាប់ពីម៉ោង ១១ និង៣០នាទីទៅ បើគិតពីរយៈពេលធ្វើដំណើរពីកន្លែងកើតហេតុទៅកន្លែងកើតហេតុជនជាប់ចោទអាចប្រើរយៈពេលតែ ១៥នាទី ទៅ ២០នាទី ប៉ុណ្ណោះ អាចគេចចេញមកដល់ក្នុងភូមិវិញបាន។ ជនរងគ្រោះស្គាល់ច្បាស់អ្នកដែលបាញ់ខ្លួនគឺជាជនជាប់ចោទឈ្មោះ[redacted] នេះបញ្ជាក់ឱ្យឃើញថាជនជាប់ចោទក្រោយពេលប្រព្រឹត្តបទល្មើស ហើយក៏ជិះម៉ូតូមកភូមិវិញ ហើយបែកគ្នាដើម្បីបំភ័ន្តសមត្ថកិច្ចមិនឲ្យចាប់អារម្មណ៍ដល់ខ្លួន ម្យ៉ាងទៀត ជនជាប់ចោទមិននឹកស្មានថាជនរងគ្រោះនៅមានដង្ហើម អាចនិយាយបានទើបបានជាមិនរត់គេចខ្លួន។

១០-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ ២៦ឆ្នាំ និងជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ ៤១ឆ្នាំ ពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ១១-៦-២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-សេចក្តីសម្រេចនៃសាលក្រមលេខ ០៤ "ជ" ចុះថ្ងៃទី ០៩-០២-២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ មានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់ឡើយ គប្បីបដិសេធចោល។

-មេធាវីការពារជនជាប់ចោទ បានបញ្ជាក់ថា ជនជាប់ចោទទាំងពីរបានទទួលដំណឹងពីកាលបរិច្ឆេទនៃសវនាការនៃសវនាការរួចហើយ តែអវត្តមានដូចនេះសាលដីកានេះត្រូវប្រកាសថា កំបាំងមុខជនជាប់ចោទ ចាត់ទុកជាចំពោះមុខ។ តាមមាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ហេតុដូច្នេះ**

**ទនិច្ឆ័យសេចក្ត**

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១០ របស់ឈ្មោះ[redacted]ជាតំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ០៤ "ជ" ចុះថ្ងៃទី ០៩-០២-២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ចោល។

៣-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]ប អាយុ២៦ឆ្នាំ និងជនជាប់ចោទឈ្មោះ[redacted]ទប្រុស អាយុ ៤៨ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗកំណត់ ១៧ឆ្នាំ ពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្ត



Scanned by CamScanner

នៅភូមិសាលាត់រួ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ១១-៦-២០០៩ ។ តាមមាត្រា ៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៣៥០ ចំណុច ១,២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-បង្គាប់ឲ្យជនជាប់ចោទ[redacted]ងជម្ងឺចិត្តចំនួន ២០.០០០.០០០រ ម្ភៃលានរៀល ទៅដើមបណ្ដឹងឈ្មោះ [redacted] ការទាមទារលើសពីនេះបដិសេធចោល។

-បង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ[redacted]កអនុវត្តទោសនៅពន្ធនាគារខេត្តពោធិ៍សាត់ តាមអំណាចសាលដីកានេះ។ តាមមាត្រា ៤០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ២០-៦-២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៧-៧-២០១២ ដោយសម្រេចសេចក្ដី:

-កំបាំងមុខជនជាប់ចោទឈ្មោះ[redacted]ះមុខមេធាវីការពារចាត់ទុកជាចំពោះមុខ

-កំបាំងមុខដើមបណ្ដឹង ចំពោះមុខមេធាវី

-បើកសិទ្ធិប្ដឹងតវ៉ា តាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 30 ខែ 8 ឆ្នាំ២០១២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned by CamScanner